**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ០០១ ស.សរ អ.ជ.ប.គ.ញ.

# សេចក្ដីសម្រេច
## ស្ដីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន

## ឧបនាយករដ្ឋមន្ត្រី
## ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពី ការកែសម្រួលមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៣១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ. មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

# សម្រេច

**ប្រការ១ .–**

សេចក្តីសម្រេចនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន Border Liaison Office( BLO ) សរសេរអក្សរកាត់ថា "ការិយាល័យ BLO" នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ប្រការ២ .–**

ការិយាល័យ BLO បច្ចុប្បន្ន មានចំនួន ២០ (ម្ភៃ) ដូចខាងក្រោម៖

| | |
|---|---|
| ១. ការិយាល័យ BLO បាវិត | ខេត្តស្វាយរៀង |
| ២. ការិយាល័យ BLO ក្អមសំណរ | ខេត្តកណ្តាល |
| ៣. ការិយាល័យ BLO ជ្រៃធំ | ខេត្តកណ្តាល |
| ៤. ការិយាល័យ BLO ភ្នំដិន | ខេត្តតាកែវ |
| ៥. ការិយាល័យ BLO ព្រែកចាក | ខេត្តកំពត |
| ៦. ការិយាល័យ BLO ចាំយាម | ខេត្តកោះកុង |
| ៧. ការិយាល័យ BLO ព្រំ | ខេត្តប៉ៃលិន |
| ៨. ការិយាល័យ BLO ដូង | ខេត្តបាត់ដំបង |
| ៩. ការិយាល័យ BLO ប៉ោយប៉ែត | ខេត្តបន្ទាយមានជ័យ |
| ១០. ការិយាល័យ BLO ជប់គគីរ | ខេត្តឧត្តរមានជ័យ |
| ១១. ការិយាល័យ BLO អូរស្មាច់ | ខេត្តឧត្តរមានជ័យ |
| ១២. ការិយាល័យ BLO ជាំ | ខេត្តឧត្តរមានជ័យ |
| ១៣. ការិយាល័យ BLO អានសេះ | ខេត្តព្រះវិហារ |
| ១៤. ការិយាល័យ BLO កំពង់ស្រឡៅ | ខេត្តព្រះវិហារ |
| ១៥. ការិយាល័យ BLO ព្រះរំកិល(ភូមិលើអន្លង់ស្វាយ) | ខេត្តស្ទឹងត្រែង |
| ១៦. ការិយាល័យ BLO អូរស្វាយ(កោះឈើទាលធំ) | ខេត្តស្ទឹងត្រែង |
| ១៧. ការិយាល័យ BLO ត្រពាំងក្រៀល(ដុងក្រឡ) | ខេត្តស្ទឹងត្រែង |
| ១៨. ការិយាល័យ BLO អូរយ៉ាដាវ | ខេត្តរតនគិរី |
| ១៩. ការិយាល័យ BLO ត្រពាំងផ្លុង | ខេត្តត្បូងឃ្មុំ |
| ២០. ការិយាល័យ BLO កោះរកា | ខេត្តព្រៃវែង។ |

ការិយាល័យ BLO អាចនឹងត្រូវបានបង្កើតបន្ថែមតាមការចាំបាច់។

**ប្រការ៣ .–**

ការិយាល័យ BLO មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. អភិបាលរងខេត្តដែលមានការិយាល័យ BLO ១រូប | ប្រធាន |
| ២. អភិបាលក្រុង/ស្រុកជាប់ព្រំដែនដែលមានការិយាល័យ BLO | អនុប្រធាន |
| ៣. ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្ត ១រូប | អនុប្រធានអចិន្ត្រៃយ៍ |

៤. តំណាងនាយកដ្ឋានអនុវត្តច្បាប់នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប អនុប្រធាន
៥. ប្រធានស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិ អនុប្រធាន
៦. តំណាងមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាន
នគរបាលជាតិ ១រូប សមាជិក
៧. នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក
៨. ប្រធានស្នាក់ការគយនិងរដ្ឋាករប្រចាំច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក
៩. មេបញ្ជាការរង នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ១រូប សមាជិក
១០. មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក សមាជិក
១១. មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនទឹក សមាជិក
១២. មន្ត្រីទទួលបន្ទុកបូកសរុបរបាយការណ៍នៃលេខាធិការដ្ឋានគណៈកម្មាធិការ
ត្រួតពិនិត្យគ្រឿងញៀនខេត្ត លេខាធិការ។

សមាសភាពជាក់ស្តែងនៃការិយាល័យ BLO អាចមានការប្រែប្រួលតាមទីតាំងភូមិសាស្ត្រ និងតម្រូវការជាក់ស្តែងនៃខេត្តនីមួយៗ។ សមាសភាពសមាជិកការិយាល័យ BLO ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត។

**ប្រការ៤ .-**

ការិយាល័យ BLO មានភារកិច្ចដូចខាងក្រោម៖

- ធ្វើជាសេនាធិការឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ដើម្បីទំនាក់ទំនងជាមួយប្រទេសជាប់ព្រំដែនក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សហការជាមួយការិយាល័យ BLO ទល់មុខនៃប្រទេសជាប់ព្រំដែន និងមន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធក្នុងការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ដើម្បីទប់ស្កាត់ បង្ក្រាប ការចរាចរគ្រឿងញៀន និងសារធាតុគីមីផ្សំខុសច្បាប់ និងឧក្រិដ្ឋកម្មឆ្លងដែន
- ដឹកនាំ គ្រប់គ្រង ជំរុញ និងសម្របសម្រួលការអនុវត្តការងាររបស់ការិយាល័យ BLO
- រៀបចំចាត់តាំងឱ្យមានមន្ត្រីប្រចាំការនៅការិយាល័យ BLO ជាប្រចាំ និងមានរបបប្រជុំត្រួតពិនិត្យការងារប្រចាំខែជាទៀងទាត់ និងមានរបាយការណ៍ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមរយៈអគ្គលេខាធិការដ្ឋាន នៃអ.ជ.ប.គ.ញ.
- សហការចូលរួមអនុវត្តសកម្មភាពការិយាល័យ BLO តាមជំនាញ និងសមត្ថកិច្ចរៀងៗខ្លួន ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន
- លើកសំណើជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមរយៈអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ. ក្នុងករណីមានការកែសម្រួលសមាសភាពការិយាល័យ BLO
- សម្របសម្រួលការងារពាក់ព័ន្ធភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀននៅតាមព្រំដែន
- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតតាមការណែនាំជាក់ស្តែងរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ប្រការ៥ .–**

ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ត្រូវទទួលខុសត្រូវក្នុងការរៀបចំស្នាក់ការនិងធានានិរន្តរភាពការងារនៃការិយាល័យ BLO ក្នុងខេត្តរបស់ខ្លួន។

**ប្រការ៦ .–**

អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ. ដែលមាននាយកដ្ឋានអនុវត្តច្បាប់ជាសេនាធិការ មានភារកិច្ចដឹកនាំ គ្រប់គ្រង ជំរុញ សម្របសម្រួលការអនុវត្តការិយាល័យ BLO ដូចមានចែងក្នុងប្រការ៤ និងមានសិទ្ធិអន្តរាគមន៍ក្នុងករណីចាំបាច់។

**ប្រការ៧ .–**

សេចក្តីសម្រេចលេខ០០៤ ស.ស.រ អ.ជ.ប.គ.ញ. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .–**

អនុប្រធាន សមាជិក សមាជិកា នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត គ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ✓

ថ្ងៃ សុក្រ ១៣ រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

សន្តិបណ្ឌិត.នេត.សាវឿន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសន្តិបណ្ឌិតឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- ឯកសារ កាលប្បវត្តិ